ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ ៦១៤ "ក"
ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ ៣៣៣០
ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១
-សុំបសួរលេខ ២៥៧០
ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២១
-ជំនុំជម្រះលេខ ៤៤៦៩
ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង១៤ រសៀល នៅសាលសវនាការទី២ ដោយមានសមាសភាព៖

ចៅក្រមជំនុំជម្រះ

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៣៣០ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ដែលមានជនជាប់ចោទឈ្មោះ [redacted] **វិចិត្រា ហៅលិក** ភេទប្រុស **អាយុ ២៩ឆ្នាំ** ជនជាតិខ្មែរ កម្រិតវប្បធម៌ថ្នាក់ទី១១ មុខរបរចុងភៅ សាសនាព្រះពុទ្ធ ទីកន្លែងកំណើត [redacted] ខេត្តកោះកុង ទីលំនៅមុនពេលឃុំខ្លួនផ្ទះលេខ១៩ បុរីពិភពថ្មី៣ ផ្លូវ១០បេ ភូមិកន្ទោក សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] **សុខុម (ឡែងលេះ)** "រស់" មានកូន**០២** នាក់ ឪពុកឈ្មោះ [redacted] **សុធា** "រស់" ម្តាយឈ្មោះ [redacted] **វណ្ណសារ៉ាវី** "រស់" ជានីតិជន ទោសពីមុន គ្មាន ។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ **៥៨៣៦** "ម"ដ.ឃ.ដ ចុះថ្ងៃទី**២២** ខែសីហា ឆ្នាំ**២០២១** ។

ជាប់ចោទពីបទ **គំរាមកំហែងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៩ ផ្លូវលេខ១០ បេ បុរីពិភពថ្មីទី៣ ភូមិកន្ទោក សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ**២០២១** បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា **២៣២** នៃក្រមព្រហ្មទណ្ឌ ។

-មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុផេង** ភេទស្រី អាយុ ២១ឆ្នាំ មានទីលំនៅផ្ទះលេខ៣០៦ ក្រុម០៧ ភូមិបល្ល័ង សង្កាត់វត្តរការ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ។

អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ នៅចំណុចផ្ទះលេខ១៩ ផ្លូវលេខ១០B បុរីពិភពថ្មីទី៣ ភូមិកន្ទោក សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] **វិចិត្រា** បានយកទូរស័ព្ទរបស់ជនរងគ្រោះឈ្មោះ [redacted] **សុផេង** ភេទស្រី អាយុ ២១ឆ្នាំ មកថតជាឃ្លីបវីដេអូពេលរួមភេទជាមួយជនរងគ្រោះ រួចផ្ញើវីដេអូនេះតាមប្រព័ន្ធតេឡេក្រាមទៅផ្ទុកក្នុងទូរស័ព្ទរបស់ខ្លួន ។ ជនជាប់ចោទបានយកវីដេអូដែលបានថតទុកខាងលើ មកគំរាមកំហែងជនរងគ្រោះឱ្យរួមភេទជាមួយខ្លួន បើមិនព្រមរួមភេទជាមួយជនជាប់ចោទទេ ជនជាប់ចោទនឹងផ្ញើវីដេអូរួមភេទទៅឱ្យក្រុមគ្រួសារជនរងគ្រោះ និងសាធារណៈជនតាមប្រព័ន្ធសង្គមតេលេក្រាមនិងហ្វេសបុក ។ រហូតដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ ជនរងគ្រោះបានដាក់ពាក្យបណ្តឹងនៅការិយាល័យប្រឆាំងការជួញដូរមនុស្ស ដើម្បីចាត់ការតាមនីតិវិធីច្បាប់តែម្តង ។

Scanned with CamScanner

- បានឃើញរបាយការណ៍សរុបលេខ ០៣០/**២២ រ.ប.ក** ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ ។
- **បានឃើញ** កំណត់ហេតុស្តីពីការស្តាប់ចម្លើយដើមបណ្តឹងឈ្មោះ [redacted] **សុផេង** ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។
- **បានឃើញ** កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទឈ្មោះ [redacted] **វិចិត្រា** ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។
- **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៥៧៦ **អ.ឃ.ណ** ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។
- **បានឃើញ** ដីកាសន្និដ្ឋានស្តាពរលេខ **៤១៥៩ អ.ឃ.ណ** ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។
- **បានឃើញ** ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៥៨៩០ "ថ"ដ.ដ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **វិចិត្រា** ហៅ **លិក** បានឆ្លើយថា៖ ខ្លួន និងឈ្មោះ [redacted] **សុផេង** បានស្គាល់គ្នាតាមហ្វេសបុក រួចក៏មានទំនាក់ទំនងគ្នាជាសង្សារ ហើយក៏បានណាត់ជួបគ្នារួមភេទនៅផ្ទះសំណាក់ជាច្រើនលើក ។ នៅថ្ងៃទី ២២-២៣ ខែមិថុនា ឆ្នាំ២០២១ ខ្លួនបានណាត់ជនរងគ្រោះដើម្បីរួមភេទ នៅផ្ទះសំណាក់ឈូកទិព្វ ខេត្តបាត់ដំបង ហើយក៏បានយកទូរស័ព្ទម៉ាក OPPO A39 ពណ៌ទឹកប្រាក់របស់ខ្លួន ថតសកម្មភាពពេលរួមភេទជាមួយគ្នាបានប្រហែល ៤ ទៅ ៥ វីដេអូឃ្លីប ដោយមានការយល់ព្រមពីជនរងគ្រោះ ។ លុះព្រឹកឡើងខ្លួនក៏បានណាត់ជនរងគ្រោះមករួមភេទនៅផ្ទះសំណាក់ដដែល ហើយក៏បានមើលវីដេអូដែលថតទុកនោះជាមួយគ្នា ដោយខ្លួនឃើញជនរងគ្រោះមិនសប្បាយចិត្ត ក៏បានលុបវីដេអូរួមភេទលើកមុនចោល និងបានយកទូរស័ព្ទរបស់ជនរងគ្រោះថតសកម្មភាពរួមភេទ ជាមួយគ្នាថ្មីជាច្រើនឃ្លីបទៀត។ ក្រោយមកជនរងគ្រោះក៏បានផ្តាច់ទំនាក់ទំនងជាមួយខ្លួន ដល់អំឡុងថ្ងៃទី២៨,២៩ ខែមិថុនា ឆ្នាំ២០២១ ខ្លួនបានដឹងថាជនរងគ្រោះ បានទៅត្រអូរគ្នាជាមួយសង្សារចាស់វិញ ខ្លួនក៏បានផ្ញើសារតាមប្រព័ន្ធតេឡេក្រាម ទៅគំរាមជនរងគ្រោះថា *"ធ្វើឱ្យខ្ញុំឈឺចាប់ ខ្ញុំនឹងធ្វើឱ្យពួកអ្នកឯងឈឺចាប់ទាំងអស់គ្នា"* ។ នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ខ្លួនបានណាត់ជនរងគ្រោះទៅជួបនៅផ្ទះសំណាក់ដដែល ហើយក៏បានសុំជនរងគ្រោះរួមភេទជាលើកចុងក្រោយ តែជនរងគ្រោះមិនព្រម ពេលនោះខ្លួនក៏បានគំរាមថាបើមិនព្រមរួមភេទជាមួយខ្លួនទេ មិនឱ្យចេញពីបន្ទប់ទេ និងបានលួងលោមជនរងគ្រោះរហូតរួមភេទបានសម្រេច។ ខ្លួនពិតជាបានយកវីដេអូឃ្លីបពីសកម្មភាពខ្លួនរួមភេទជាមួយជនរងគ្រោះ ចម្លងទុកនៅក្នុងទូរស័ព្ទរបស់ខ្លួនទាំងអស់ចំនួន១៦វីដេអូឃ្លីប ទុកដើម្បីគំរាមជនរងគ្រោះប្រាកដមែន ។

-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] **សុផេង** បានឆ្លើយថា៖ ខ្លួន និងជនត្រូវចោទឈ្មោះ [redacted] **វិចិត្រា** បានស្គាល់គ្នានៅអំឡុងខែតុលា ឆ្នាំ២០២០ ។ ក្រោយពីមានទំនាក់ទំនងគ្នាជាសង្សារបានប្រហែលមួយខែក៏ណាត់គ្នាដើរលេងនៅខេត្តកោះកុង និងបានរួមភេទជាមួយគ្នានៅទីនោះ ។ ក្រោយមកទៀតខ្លួន និងឈ្មោះ [redacted] **វិចិត្រា** បានរួមភេទជាមួយគ្នាជាច្រើនដងនៅផ្ទះសំណាក់ក្នុងខេត្តបាត់ដំបង ហើយឈ្មោះ [redacted] **វិចិត្រា** បានសុំខ្លួនថតសកម្មភាពពេលរួមភេទជាមួយគ្នាទុកផងដែរ ។ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ឈ្មោះ [redacted] **វិចិត្រា** បានណាត់ខ្លួនទៅផ្ទះសំណាក់ម្តងទៀត ហើយបានសុំខ្លួនរួមភេទ និងគំរាមខ្លួនថា បើមិនព្រមរួមភេទជាមួយគេទេ គេនឹងបង្ខាំងខ្លួនទុកក្នុងផ្ទះសំណាក់ និងបង្ហោះវី

ដេអ្នរួមភេទជាមួយគ្នាកន្លងមកឱ្យក្រុមគ្រួសារខ្លួនដឹង ។ បន្ទាប់ពីរួមភេទរួចឈ្មោះ [redacted] **វិចិត្រា** បានទាមទារយកទូរស័ព្ទដែលគេបានទិញឱ្យខ្លួនកន្លងមក ដោយក្នុងទូរស័ព្ទនោះមានវីដេអ្នរួមភេទជាមួយគ្នា និងមានអាខោនហ្វេសបុករបស់ខ្លួនឈ្មោះ [redacted] **សុផេង** ជាប់ទៅជាមួយផងដែរ ដល់នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២១ ឈ្មោះ [redacted] **វិចិត្រា** បានយកអាខោនរបស់ខ្លួនផ្ញើវីដេអ្នរួមភេទខាងលើ ទៅអាខោនហ្វេសបុកបងស្រីរបស់ខ្លួនឈ្មោះ [redacted] **ផា** និងផ្ញើទៅមិត្តភក្តិរបស់ខ្លួនបីនាក់ផ្សេងទៀត រហូតដល់ខ្លួនប្តឹងឱ្យសមត្ថកិច្ចឃាត់ខ្លួន ។ សំណូមពរសុំទាមទារសំណងជំងឺចិត្តចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក ។

-ពាក្យសុំដកពាក្យបណ្តឹង ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] **សុផេង** ស្នើសុំដកពាក្យបណ្តឹងឈប់ប្តឹងឈ្មោះ [redacted] **វិចិត្រា** ភេទប្រុស អាយុ ២៩ឆ្នាំ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៣៣៣០ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ដោយមូលហេតុខាងភាគីជនជាប់ចោទបានសម្រុះសម្រួល សងសំណងជំងឺចិត្តដល់រូបខ្លួនរួចហើយ ។

សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន ឆ្លងតាមការសាកសួរនាពេលសវនាការនេះ ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះ ឃើញថា ជនជាប់ចោទបានឆ្លើយសារភាពអស់ហើយនូវអំពើប្រព្រឹត្តរបស់ខ្លួន ដែលចម្លើយនេះស៊ីសង្វាក់ទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះព្រមទាំងភស្តុងតាងក្នុងសំណុំរឿង ពិតជាមានអង្គហេតុ **គំរាមកំហែងដោយមានបញ្ហាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ** នៅចំណុចផ្ទះលេខ១៩ ផ្លូវលេខ១០បេ បុរីពិភពថ្មីទី៣ ភូមិកន្ទោក សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ ដែលប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] **វិចិត្រា** ភេទប្រុស អាយុ ២៩ឆ្នាំ ព្រាកដមែន ។ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់លើជនជាប់ចោទ តាមដីកាសន្និដ្ឋានស្តាពរលេខ **៤១៥៩ អ.យ.ណ** ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ ដដែល និងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមការសាកសួរនាពេលសវនាការនេះឃើញថា ជនជាប់ចោទបានឆ្លើយសារភាព និងទទួលកំហុសគ្រប់បែបយ៉ាង ព្រមទាំងសងសំណងទៅជនរងគ្រោះ ហើយជនជាប់ចោទទើបតែប្រព្រឹត្តបទល្មើសជាលើកទី១ និងមានម្តាយឈឺនៅផ្ទះដូចនេះសូមឱ្យតុលាការពិចារណាផ្តល់ស្តានសម្រាលទោសដល់ជនជាប់ចោទ ដើម្បីឱ្យជនជាប់ចោទធាប់ចេញពីពន្ធនាគារទៅរកប្រាក់សងសំណងជនទៅជនរងគ្រោះ និងមើលថែម្តាយដែលមានជំងឺ ។

សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] **វិចិត្រា** សំណូមពរចុងក្រោយ ខ្លួនបានដឹងនូវកំហុសហើយ សុំឱ្យតុលាការជួយបន្ធូបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមផ្លូវច្បាប់ហើយ

<u>**សំអាងហេតុ**</u>

១-កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ ស្ថិតនៅចំណុចផ្ទះលេខ១៩ ផ្លូវលេខ១០បេ បុរីពិភពថ្មីទី៣ ភូមិកន្ទោក សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ ពិតជាមានអង្គហេតុ **គំរាមកំហែងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ** ខណៈជនជាប់ចោទឈ្មោះ [redacted] **វិចិត្រា** ហៅ **លិក** និងជនរងគ្រោះឈ្មោះ [redacted] **សុផេង** ជាសង្សារនឹងគ្នា ក្រោយមកជនរងគ្រោះក៏បានផ្តាច់ទំនាក់ទំនងជាមួយជនជាប់ចោទ ជនជាប់ចោទក៏ផ្ញើសារតាមប្រព័ន្ធតេឡេក្រាម ទៅគំរាមជនរងគ្រោះថា **"ធ្វើឱ្យខ្ញុំឈឺចាប់ ខ្ញុំនឹងធ្វើឱ្យពួកអ្នកឯងឈឺចាប់ទាំងអស់គ្នា"** និងបានយកវីដេអូឃ្លីបពីសកម្មភាពរួមភេទជាមួយជនរងគ្រោះ ចម្លងទុកនៅក្នុងទូរស័ព្ទរបស់ខ្លួន ទុកដើម្បីគំរាមជនរងគ្រោះប្រាកដមែន ។

២-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **វិចិត្រា** ហៅ **លិក** បានឆ្លើយសារភាពថា ខ្លួន និងជនរងគ្រោះឈ្មោះ [redacted] **សុផេង** ជាសង្សារគ្នា ហើយក៏បានណាត់ជួបគ្នារួមភេទនៅផ្ទះសំណាក់ជាច្រើនលើក និងបានថតសកម្មភាពពេលរួមភេទជាមួយគ្នា ។ ក្រោយមកជនរងគ្រោះក៏បានផ្តាច់ទំនាក់ទំនងជាមួយខ្លួន ដោយជនរងគ្រោះទៅត្រូវរ៉ូវគ្នាជាមួយសង្សារចាស់វិញ ខ្លួនក៏បានផ្ញើសារតាមប្រព័ន្ធតេឡេក្រាម ទៅគំរាមជនរងគ្រោះថា *"ធ្វើឱ្យខ្ញុំឈឺចាប់ ខ្ញុំនឹងធ្វើឱ្យពួកអ្នកឯងឈឺចាប់ទាំងអស់គ្នា"* និងយកវីដេអូឃ្លីបពីសកម្មភាពខ្លួនរួមភេទជាមួយជនរងគ្រោះ ចម្លងទុកនៅក្នុងទូរស័ព្ទរបស់ខ្លួនទុកដើម្បីគំរាមជនរងគ្រោះមករួមភេទជាមួយខ្លួនប្រាកដមែន ។ ចម្លើយនេះស្របទៅនឹងចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **សុផេង** ដែលបានឆ្លើយបញ្ជាក់ថា ខ្លួន និងឈ្មោះ [redacted] **វិចិត្រា** ជាសង្សារគ្នា និងបានសុំខ្លួនថតសកម្មភាពពេលរួមភេទជាមួយគ្នាទុកផងដែរ ក្រោយមកខ្លួនក៏សុំបែកគ្នា ។ ដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ឈ្មោះ [redacted] **វិចិត្រា** បានណាត់ខ្លួនទៅផ្ទះសំណាក់សុំខ្លួនរួមភេទ និងគំរាមខ្លួនថា បើមិនព្រមរួមភេទជាមួយទេ គេនឹងបង្ហោះវីដេអូរួមភេទជាមួយគ្នាកន្លងមក ឱ្យក្រុមគ្រួសារខ្លួន និងផ្ញើទៅមិត្តភក្តិរបស់ខ្លួន ។ តុលាការយល់ឃើញថា អំពើរបស់ជនជាប់ចោទ គឺជាការគំរាមកំហែងក្រោមទម្រង់ប្រឆាំងនឹងបុគ្គល ជាបទល្មើសគំរាមកំហែងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ មានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៣២ នៃក្រមព្រហ្មទណ្ឌ ។

៣-តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនិងជាជនរងគ្រោះឃើញថា ជនជាប់ចោទបានឆ្លើយសារភាពអស់ហើយនូវអំពើប្រព្រឹត្តរបស់ខ្លួន ដែលចម្លើយនេះស៊ីសង្វាក់នឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពិតជាមានអង្គហេតុ គំរាមកំហែងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ នៅចំណុចផ្ទះលេខ១៩ ផ្លូវលេខ១០បេ បុរីពិភពថ្មីទី៣ ភូមិកន្ទោក សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ ដែលប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] **វិចិត្រា** ភេទប្រុស អាយុ ២៩ ឆ្នាំ ប្រាកដមែន សុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ តុលាការគប្បីពិចារណា ។

៤-ជនជាប់ចោទឈ្មោះ [redacted] **វិចិត្រា** ហៅ **លិក** ភេទប្រុស អាយុ ២៩ឆ្នាំ និងជាសមត្ថជនមានស្មារតីជានាល្អ យល់ដឹងគ្រប់គ្រាន់ពេលប្រព្រឹត្តបទល្មើស (គ្មានវិបល្លាសស្មារតី) ដែលអាចទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួនបាន។

៥-វត្ថុចាប់យកមានតាមកំណត់ហេតុទទួលវត្ថុចាប់យក(១) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១ របស់ក្រឡាបញ្ជីទទួលបន្ទុកឃ្លាំងវត្ថុចាប់យកមាន: ទូរស័ព្ទដៃចំនួនពីរគ្រឿង ម៉ាក OPPO ពណ៌មាស និងម៉ាក SAMSUNG ពណ៌ខ្មៅ តុលាការគប្បីប្រគល់ឱ្យម្ចាស់ដើមវិញ ។

៦-មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] **វិចិត្រា** ហៅ **លិក** ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ ពីបទ **គំរាមកំហែងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៩ ផ្លូវលេខ១០បេ បុរីពិភពថ្មីទី៣ ភូមិកន្ទោក សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៣២ នៃក្រមព្រហ្មទណ្ឌ ។

Scanned with CamScanner

៧-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] **សុផេង** ផ្អែកតាមពាក្យសុំដកពាក្យបណ្តឹង ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ ស្នើសុំដកពាក្យបណ្តឹងឈប់ប្តឹងឈ្មោះ [redacted] **វិចិត្រា** ភេទប្រុស អាយុ ២៩ឆ្នាំ ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ ៣៣៣០ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ដោយមូលហេតុខាងភាគីជនជាប់ចោទបានសម្រុះសម្រួល សងសំណងជំងឺចិត្តដល់រូបខ្លួនរួចហើយ ដូចនេះតុលាការពុំគប្បីពិចារណាលើសំណងរដ្ឋប្បវេណីឡើយ ។

ហេតុផ្លូវច្បេះសម្រេច

១-ផ្តន្ទាទោសលើឈ្មោះ [redacted] **វិចិត្រា** ហៅ **លិក** ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) **រៀល** ពីបទ **គំរាមកំហែងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៩ ផ្លូវលេខ១០បេ ប៊ុរីពិភពថ្មីទី៣ ភូមិកន្ទោក សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា**៣៣២** នៃក្រមព្រហ្មទណ្ឌ។

២-វត្ថុចាប់យកមាន ទូរស័ព្ទដៃចំនួនពីរគ្រឿង ម៉ាក OPPO ពណ៌មាស និងម៉ាក SAMSUNG ពណ៌ខ្មៅ ប្រគល់ទៅឱ្យម្ចាស់ដើមវិញ ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី**២៨** ខែ**កុម្ភៈ** ឆ្នាំ**២០២២** ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីនិងជាជនរងគ្រោះ ប្រកាសជាសាធារណៈនៅថ្ងៃទី**១៥** ខែ**មីនា** ឆ្នាំ**២០២២** បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ៕

ក្រឡាបញ្ជីសវនាការ

ហត្ថលេខានិងត្រា [redacted]

ចៅក្រមជំនុំជម្រះ

ហត្ថលេខានិងត្រា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១៣កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

ព្រមទាំង

ចៅក្រមជំនុំជម្រះ

[redacted]

Scanned with CamScanner